សប្តាហ៍ទី 4

ណូអេ និងទូកធំ

ខ្ញុំបានធ្វើការសន្យារបស់ព្រះ និងស្តាប់បង្គាប់

រឿងក្នុងព្រះគម្ពីរ

ណូអេបានធ្វើទូកធំតាមបញ្ជារបស់ព្រះជាម្ចាស់, គាត់ជឿថាភ្លៀងធំនឹងធ្លាក់មក ហើយឱ្យក្រុមគ្រួសារ និងសត្វចូលក្នុងទូក។ ព្រះបានសន្យាជាមួយណូអេ និងបង្ហាញឥន្ទធនូ ហើយបានសន្យាថានឹងមិនជំនុំជម្រះផែនដីដោយសារទឹកទៀតឡើយ។

សមិទ្ធផលសម្រេច



ព្រះជាម្ចាស់បានសន្យាជាមួយណូអេ និងបង្ហាញឥន្ទធនូ ហើយបានសន្យាថានឹងមិនជំនុំជម្រះផែនដីដោយសារទឹកទៀតទេ។

វត្ថុបំណង

- ដឹងអំពីការស្តាប់បង្គាប់របស់លោកណូអេ និងការសន្យារបស់ព្រះជាម្ចាស់។
- ធ្វើតំណក់ទឹកភ្លៀង ដោយប្រើសំឡីត្បាល់ត្រចៀក។
- ចងចាំការសន្យារបស់ព្រះ និងមានដួងចិត្តអរព្រះគុណ។

សម្ភារៈ



របៀបធ្វើ

1 ការរៀបចំផ្នែកខាងក្រោយ



ជាត់ផ្នែកខាងក្រោមនៃក្រដាសរឹងដោយពណ៌ខៀវ ហើយជាត់ពណ៌ ឬតុបតែងទូកធំ

2 ការបង្កើតតំណក់ទឹកភ្លៀង



ជ្រលក់ថ្នាំពណ៌ពណ៌ខៀវនៅចុងសំឡីត្បាល់ត្រចៀក ផ្តិតពីខាងលើមក ដើម្បីបង្កើតជាតំណក់ទឹកភ្លៀង។

* ប្រើថ្នាំពណ៌ស្តើងៗ ដើម្បីមិនឱ្យជ្រីតពេក។

3 ការបង្កើយរូបឥន្ទធនូ



ជាត់ពណ៌គម្រូឥន្ទធនូ រួចកាត់វា បិទលើផ្នែខាងក្រោយ។

* បិទពពកផងដែរ។

4 តុបតែងណូអេ និងសត្វ



ជាត់ពណ៌ណូអេ និងសត្វផ្សេងៗ ហើយកាត់វាបិទក្នុងទូកធំ។

5 ការធ្វើរួច និងការពិភាក្សា



មើលសមិទ្ធផលដែលធ្វើរួច ហើយពិភាក្សាគ្នាអំពីការសន្យារបស់ព្រះជាម្ចាស់។

ការពង្រីកសកម្មភាព

- និយាយពីអារម្មណ៍ ឬសំឡេងថ្ងៃដែលមានភ្លៀងធ្លាក់។
- លេងហ្គេមស្វែងរកគូសត្វ។
- រៀបលំដាប់លំដោយនៃសាច់រឿងដោយប្រើបណ្ណណូអេ និងគ្រួសារ, សត្វ។

Tip សម្រាប់គ្រូ

- អាចធ្វើតំណក់ទឹកភ្លៀងដោយផ្តិតគម្លាតខុសៗគ្នា ឬផ្តិតទំហំខុសៗគ្នា ពេលផ្តិតសំឡីត្បាល់ត្រចៀក។
- សូមផ្តល់បរិមាណថ្នាំពណ៌ល្មមដល់កុមារ ដើម្បីមិនឱ្យពួកគេប្រើថ្នាំពណ៌ច្រើនលើសលុប។
- សូមផ្សាយដំណឹងល្អដោយសំណួរ៖«តើព្រះជាម្ចាស់បានសន្យាជាមួយលោកណូអេថាដូចម្តេច?»
- សូមប្រាប់កុមារថា ពេលដែលយើងចងចាំសេចក្តីសន្យារបស់ព្រះជាម្ចាស់ យើងអាចស្តាប់បង្គាប់ដោយសេចក្តីជំនឿបាន។